# សំអាងហេតុនិងសេចក្តីសម្រេច

...យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍សំរេចប្រកាសទោសនិងផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ **សវណ** ពីបទចាប់ឃុំឃាំងនិងបង្ខាំងដោយខុសច្បាប់ក្នុងគោលដៅជំរិតទារប្រាក់ និងកាន់កាប់អាវុធដោយខុសច្បាប់ មានសំអាងហេតុនិងសេចក្តីសំរេចផ្ទុយគ្នា ពីព្រោះថា តាមចម្លើយសាក្សីឈ្មោះ **ផវស** ជាអ្នកទទួលភ្ញៀវនៅសណ្ឋាគារខ្សាច់មាសនិង**យសរ** ជាអ្នកទទួលភ្ញៀវនៅបឹងកាឡូ អូរឈើទាល ពុំបានបញ្ជាក់អំពីហេតុនៃអំពើល្មើសទេ តែបញ្ជាក់អំពីការស្រុះស្រួលគ្នាមកជួលស្នាក់នៅតែប៉ុណ្ណោះ។

ដូចនេះសម្រេច....បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ (**សាលដីកាព្រហ្មទណ្ឌតុលាការកំពូលលេខ ១៥៧, ២០១៣, ទំ.៥និង៦**)។

…the fact that the Court of First Instance and the Appeal Court decided and pronounced sentence upon the accused…on with illegal confinement for the purpose of extortion and illegal possession of a weapon shows contained contradictions between the legal reasoning and the final ruling since witness testimonies from hotel and bungalow staff did not confirm the elements of a crime. Instead, their statements indicated a mutual agreement to rent and stay at the locations.

Consequently, the Supreme Court decided to remand the case (Criminal Case No. 46, dated February 26, 2013) back to the Appeal Court for a new trial.

**កំណត់សំគាល់៖** ច្បាប់បានតម្រូវថាសេចក្តីសម្រេចខ្លះ ត្រូវមានសំអាងហេតុ (reasoning)(មាត្រា៤១៖ការតម្កល់រឿងទុកឥតចាត់ការ)(មាត្រា៣៥៧ ៖ការសរសេរសាលក្រម៖ផ្នែកសំអាងហេតុនិងផ្នែកសម្រេច)។ សំអាងហេតុត្រូវមានភាពត្រឹមត្រូវ និងច្បាស់លាស់(មាត្រា២១០៖ការឃុំខ្លួនបណ្តោះអាសន្ន)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧, មាត្រា៤១៩៖ មូលហេតុនៃបណ្តឹងសាទុក្ខ (តុលាការកំពូល អាចបដិសេធសេចក្តីសម្រេច ក្នុងករណីដូចតទៅ) ៖...-***ការផ្ទុយគ្នារវាងសំអាងហេតុនិងសេចក្តីសម្រេច***។

វិធានសិទ្ធិមនុស្សស្តីពីការកាត់សេចក្តីដោយយុត្តិធម៌ តម្រូវឲ្យមានសេចក្តីសម្រេចមានសំអាងហេតុផងដែរ ដើម្បីឲ្យភាគីងាយស្រួលក្នុងការប្តឹងឧទ្ធរណ៍ជាដើម។